# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ** ៥៦៥/០៦ **គ.ជ.ប**

## សេចក្តីណែនាំ
## ស្តីពី
## ករណីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២ ឆ្នាំ ២០០៧

**យោង** :
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- បទបញ្ជា និង នីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ ២០០៧
- សេចក្តីណែនាំលេខ ០០៤ ស.ណ.ន ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦ របស់ក្រសួងមហាផ្ទៃស្តីពី បែបបទ នីតិវិធី នៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និង តួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ ។

ដើម្បីជំរុញឱ្យដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ២ ឆ្នាំ ២០០៧ នេះ ប្រព្រឹត្តទៅបានត្រឹមត្រូវតាមច្បាប់ និងបទបញ្ជា និងនីតិវិធី គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមរំលឹក និងណែនាំដល់ក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិទាំងអស់ ដែលឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ ២០០៧ នេះ ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម :

- មិនតម្រូវឱ្យសុំច្បាប់ឈប់ពិសេសទេ
- ក្នុងតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ជាមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវប្រកាន់ជំហរអព្យាក្រឹតក្នុងការងាររបស់ខ្លួន ស្របតាមច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធដែលនៅជាធរមាន
- មិនត្រូវប្រើតួនាទី មុខងាររបស់ខ្លួន ដើម្បីកេងចំណេញផ្នែកនយោបាយឡើយ និង
- ក្នុងតួនាទីជាបេក្ខជនត្រូវគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារនៃគណបក្សនយោបាយ ហើយមិនត្រូវយកតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ជាមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិមកប្រើប្រាស់ក្នុងពេលឃោសនាបោះឆ្នោត បោះឆ្នោត និងរាប់សន្លឹកឆ្នោតទេ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សង្ឃឹមទុកជាមុនថា សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ដែលឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្តតាមសេចក្តីណែនាំនេះ ដើម្បីជំរុញឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ប្រកបដោយជោគជ័យ ។

ភ្នំពេញ ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ ២០០៦

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**អ៊ឹម-សួស្តី**

**ចម្លងជូន :**
- ក្រសួងមហាផ្ទៃ "**ដើម្បីជូនជ្រាប**"
- គណបក្សនយោបាយ "**ដើម្បីជូនជ្រាប**"
- គខ/កប "**ដើម្បីផ្សព្វផ្សាយ ដល់ គឃ/សប**"
- ឯកសារ-កាលប្បវត្តិ